ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០៣០ សហវ.ប្រក

ភ្នំពេញ ថ្ងៃទី២៧ ខែមករា ឆ្នាំ ២០១១

# ប្រកាស

## ស្តីពី

## ការបង្កើតគណៈកម្មការសម្របសម្រួល និង អង្គភាពគ្រប់គ្រង និងសម្របសម្រួលការអនុវត្ត គម្រោងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ និងបង្កើនផលិតភាពកសិកម្ម ក្រោមថវិកាបន្ថែមពីការសហមូលនិធិរូបិយវត្ថុអន្តរជាតិ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ ស្តីពីការដាក់អោយប្រើប្រាស់នូវនីតិវិធីរួមសម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី
- បានឃើញប្រកាសលេខ ៩៧៥ សហវ.ប្រក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ

- បានឃើញប្រកាសលេខ ៦១៧ សហវ.ប្រក ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៨ ស្តីពីការបង្កើតក្រុមការងារសន្តិសុខស្បៀងថ្នាក់ជាតិសម្រាប់អនុវត្តគម្រោងឧបត្ថម្ភស្បៀងបន្ទាន់ និងត្រូវបានបំពេញបន្ថែមដោយប្រកាសលេខ ៤៧៤ សហវ.ប្រក ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៩ ស្តីពីការប្រគល់ភារកិច្ចដល់ក្រុមការងារសន្តិសុខស្បៀងថ្នាក់ជាតិសម្រាប់អនុវត្តគម្រោងឧបត្ថម្ភស្បៀងបន្ទាន់ ឱ្យទទួលបន្ទុកបន្ថែមសម្រាប់អនុវត្តប្រតិបត្តិការគោលនយោបាយអភិវឌ្ឍន៍កសិកម្មខ្នាតតូច និងការគាំពារសង្គម ។

## សម្រេច

**ប្រការ១:** បង្កើតគណៈកម្មការសម្របសម្រួល និង អង្គភាពគ្រប់គ្រង និងសម្របសម្រួលការអនុវត្តគម្រោងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ និងបង្កើនផលិតភាពកសិកម្មក្រោមថវិកាបង្វែរពីការសងមូលនិធិរូបិយវត្ថុអន្តរជាតិ ។

**ប្រការ២:** គណៈកម្មការសម្របសម្រួលមានសមាសភាពដូចខាងក្រោម:

| | | |
|---|---|---|
| ១- **ឯកឧត្តម វង្សី វិស្សុត** | អគ្គលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២- នាយកគម្រោង និងអ្នកគ្រប់គ្រងទទួលបន្ទុកអនុវត្តសមាសភាគអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ | | សមាជិក |
| ៣- នាយកគម្រោង និងអ្នកគ្រប់គ្រងទទួលបន្ទុកអនុវត្តសមាសភាគបង្កើនផលិតភាពកសិកម្ម | | សមាជិក |
| ៤- **លោក ប៉ែន ធីរុង្គ** | អនុប្រធានទី១ នាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ | សមាជិក |
| ៥- **លោក រស់ បរម** | អនុប្រធាននាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ | លេខាធិការ |

**ប្រការ៣:** គណៈកម្មការសម្របសម្រួលការអនុវត្តគម្រោងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ និងបង្កើនផលិតភាពកសិកម្ម មានភារកិច្ច ដូចខាងក្រោម:

១- ផ្តល់គោលការណ៍ណែនាំ និងគោលនយោបាយពាក់ព័ន្ធនឹងការអនុវត្តគម្រោង

២- តាមដានត្រួតពិនិត្យប្រសិទ្ធភាពនៃការអនុវត្តគម្រោង

៣- ដាក់ចេញគោលការណ៍អនុវត្ត និងវិធានការដោះស្រាយរាល់បញ្ហាប្រឈមទៅនឹងការអនុវត្តគម្រោង ។ ក្នុងករណីមានវេទយិតភាព ត្រូវស្នើសុំការណែនាំពីក្រុមការងារសន្តិសុខស្បៀងថ្នាក់ជាតិសម្រាប់អនុវត្តគម្រោងឧបត្ថម្ភស្បៀងបន្ទាន់ និងអនុវត្តប្រត្តិបត្តិការគោលនយោបាយអភិវឌ្ឍន៍ កសិកម្មខ្នាតតូច និងគាំពារសង្គម

៤- រៀបចំរបាយការណ៍ស្តីពីការអនុវត្តគម្រោង ជូនក្រុមការងារសន្តិសុខស្បៀងថ្នាក់ជាតិសម្រាប់អនុវត្តគម្រោងឧបត្ថម្ភស្បៀងបន្ទាន់ និងអនុវត្តប្រត្តិបត្តិការគោលនយោបាយអភិវឌ្ឍន៍កសិកម្មខ្នាតតូច និងគាំពារសង្គម

៥- សម្របសម្រួល និងផ្តល់ការគាំទ្រដល់ការអនុវត្តគម្រោង តាមការចាំបាច់ ។

**ប្រការ៤:** គណៈកម្មការសម្របសម្រួលការអនុវត្តគម្រោងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ និងបង្កើនផលិតភាពកសិកម្ម មានអង្គភាពគ្រប់គ្រង និងសម្របសម្រួលការអនុវត្តគម្រោងជាសេនាធិការ ដែលមានសមាសភាពដូចខាងក្រោម:

| | | |
|---|---|---|
| ១- **លោក ប៉ែនធីរុង្គ** | អនុប្រធានទី១ នាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ | នាយកគម្រោង |
| ២- **លោក តូច ច័ន្ទក្រឹស្នា** | ប្រធានការិយាល័យធនាគារពិភពលោក | អ្នកគ្រប់គ្រងគម្រោង |
| ៣- **លោក ហ៊ុល បុណ្ណារ័ត្ន** | អនុប្រធានការិយាល័យធនាគារពិភពលោក | ប្រធានផ្នែកទទួលបន្ទុកសមាសភាគអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ |

៤- **លោក យង់ ស៊ី** អនុប្រធានការិយាល័យធនាគារពិភពលោក ប្រធានផ្នែកទទួលបន្ទុក សមាសភាគបង្កើនផលិតភាពកសិកម្ម

៥- **លោក ហុង ហឿន** មន្ត្រីការិយាល័យធនាគារពិភពលោក មន្ត្រីទទួលបន្ទុក សមាសភាគអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ

៦- **លោក ឱម ម៉ាក់ធារិទ្ធ** មន្ត្រីការិយាល័យធនាគារពិភពលោក មន្ត្រីទទួលបន្ទុក សមាសភាគបង្កើនផលិតភាពកសិកម្ម

**ប្រការ៥:** អង្គភាពគ្រប់គ្រង និងសម្របសម្រួលការអនុវត្តគម្រោងមានភារកិច្ចដូចខាងក្រោម:

១- ជាលេខាធិការរបស់គណៈកម្មការសម្របសម្រួលគម្រោង ក្នុងការសម្របសម្រួល និងតាមដានត្រួតពិនិត្យការអនុវត្តគម្រោង

២- គ្រប់គ្រង និងចាត់ចែងការងារហិរញ្ញវត្ថុគម្រោង

៣- ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់ការគ្រប់គ្រង និងអនុវត្តគម្រោង

៦- ស្នើឡើងនូវគោលការណ៍អនុវត្ត និងវិធានការដោះស្រាយរាល់បញ្ហាប្រឈមទៅនឹងការអនុវត្តគម្រោងជូនគណៈកម្មការសម្របសម្រួល

៧- បំពេញភារកិច្ចផ្សេងទៀតតាមការចាត់តាំងរបស់គណៈកម្មការសម្របសម្រួល ។

**ប្រការ៦:** អគ្គលេខាធិការ អគ្គលេខាធិការរង គ្រប់អគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**កន្លែងទទួល:**
- គ្រប់ថ្នាក់ដឹកនាំ នៃ កសហវ
- ក្រសួងធនធានទឹក និងឧតុនិយម
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ដូចប្រការ២ ប្រការ៤ និងប្រការ៦ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ